# រតនប្បណាម បែបសង្ខេប

## ព្រមទាំងបូជាគ្រឿងសក្ការៈ បាលីនិងប្រែ

ឥតិបិ សោ ភគវា អរហំ ព្រះដ៏មានព្រះភាគអង្គនោះទ្រង់ព្រះនាមថា អរហំ ព្រោះព្រះអង្គឆ្ងាយចាកសឹកសត្រូវពោលគឺកិលេសព្រមទាំងវាសនា គឺកាយបយោគនិងវចីបយោគ សម្មាសម្ពុទ្ធោ ទ្រង់ព្រះនាមថា សម្មាសម្ពុទ្ធោ ព្រោះព្រះអង្គ ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ វិជ្ជាចរណសម្បន្នោ ទ្រង់ព្រះនាមថា វិជ្ជាចរណសម្បន្នោ ព្រោះព្រះអង្គបរិបូណ៌ដោយវិជ្ជា៣ និង វិជ្ជា៨ និង ចរណៈ១៥ សុគតោ ទ្រង់ព្រះនាមថា សុគតោ ព្រោះព្រះអង្គមានដំណើរល្អយាងទៅកាន់ សុន្ទរស្ថានគឺ អមតមហានិព្វាន លោកវិទូ ទ្រង់ព្រះនាមថា លោកវិទូ ព្រោះព្រះអង្គជ្រាបច្បាស់នូវត្រៃលោក អនុត្តរោ ទ្រង់ព្រះនាមថា អនុត្តរោ ព្រោះព្រះអង្គប្រសើរដោយសីលាទិគុណរកបុគ្គលណាមួយស្មើគ្មាន បុរិសទម្មសារថិ ទ្រង់ព្រះនាមថា បុរិសទម្មសារថិ ព្រោះព្រះអង្គជាអ្នកទូន្មាននូវបុរសដែលមានឧបនិស្ស័យគួរនឹងទូន្មានបាន សត្ថាទេវមនុស្សានំ ទ្រង់ព្រះនាមថា សត្ថាទេវមនុ-ស្សានំ ព្រោះព្រះអង្គជាសាស្តាចារ្យ នៃទេវតានិងមនុស្សទាំងឡាយ ពុទ្ធោ ទ្រង់ព្រះនាមថា ពុទ្ធោ ព្រោះព្រះអង្គត្រាស់ដឹងនូវចតុរារិយសច្ចហើយញុំាងអ្នក ដទៃឱ្យត្រាស់ដឹងផង ភគវា ទ្រង់ព្រះនាមថា ភគវា ព្រោះព្រះអង្គមានដំណើរទៅកាន់ត្រៃ ភពខ្ចាក់ចោលហើយ គឺថា ព្រះអង្គមិនត្រឡប់កើតទៀតឡើយ តំ អរហាទិ គុណសំយុត្តំ ពុទ្ធំ សិរសា នមាមិ ខ្ញុំព្រះករុណាសូមថ្វាយបង្គំ នូវព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះអង្គប្រកបព្រមហើយដោយគុណ មានគុណថា អរហំ ជាដើមនោះ ដោយសិរសា គឺត្បូង តញ្ច ពុទ្ធំ ឥមេហិ សក្ការេហិ អភិបូជយាមិ ខ្ញុំព្រះករុណាសូមបូជាចំពោះនូវព្រះសម្មាសម្ពុទ្ធជាម្ចាស់នោះ ដោយគ្រឿងសក្ការៈទាំងឡាយ មានប្រមាណប៉ុណ្ណោះ។ (ក្រាបថ្វាយបង្គំម្តង)

ស្វាក្ខាតោ ភគវតា ធម្មោ ព្រះបរិយត្តិធម៌គឺព្រះត្រៃបិដកជាធម៌គឺព្រះដ៏មានព្រះភាគទ្រង់ត្រាស់សំដែងហើយដោយល្អ ( ធម្មោ ព្រះនព្វលោកុត្តរធម៌ មាន៩ប្រការ គឺមគ្គ៤ ផល៤ និព្វាន១ ) សន្ទិដ្ឋិកោ ជាធម៌គឺព្រះអរិយបុគ្គលទាំងពួងដឹងពិតឃើញពិតដោយបច្ចវេក្ខណញ្ញាណ គឺថានឹងបានដឹងដោយស្តាប់ដោយជឿ បុគ្គលដទៃនោះៗក៏ទេ គឺឃើញច្បាស់ដោយខ្លួនឯង អកាលិកោ ជាធម៌ឱ្យនូវផលមិនរង់ចាំកាល គឺថាកាលបើព្រះអរិយមគ្គកើតឡើងហើយព្រះអរិយផល ក៏កើតក្នុងលំដាប់គ្នា មិនបានយឺតយូរឡើង ឯហិបស្សិកោ ជាធម៌គួរដល់ ឯហិបស្សវិធី គឺថាបើព្រះអរិយបុគ្គលដែលបានសម្រេចមគ្គផលហើយ ក៏គួរនឹងហៅបុគ្គលដទៃឱ្យចូលមកមើលបាន ឱបនយិកោ ជាធម៌ គឺព្រះអរិយបុគ្គលគប្បីបង្អោនចូលមកទុកក្នុងខ្លួនដោយអំណាចនៃភាវនា បច្ចត្តំ វេទិតព្វោ វិញ្ញូហិ ជាធម៌គឺអ្នកប្រាជ្ញទាំងឡាយមានឧគ្ឃដិតញ្ញូបុគ្គលជាដើម គប្បីដឹងគប្បីឃើញច្បាស់ក្នុងចិត្តនៃខ្លួន តំ ស្វាក្ខាតាទិគុណសំយុត្តំ ធម្មំ សិរសា នមាមិ ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវព្រះធម៌ជាម្ចាស់ ដ៏ប្រកបព្រមហើយដោយគុណ មានគុណថា ស្វាក្ខាតោ ជាដើមនោះ ដោយសិរសាគឺត្បូង តញ្ច ធម្មំ ឥមេហិ សក្ការេហិ អភិបូជយាមិ ខ្ញុំព្រះករុណាសូមបូជាចំពោះនូវព្រះធម៌ជាម្ចាស់នោះ ដោយគ្រឿងសក្ការៈទាំងឡាយមានប្រមាណប៉ុណ្ណោះ ។

( ក្រាបថ្វាយបង្គំម្តង )

សុបដិបន្នោ ភគវតោ សាវកសង្ឃោ ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិហើយដោយប្រពៃ គឺប្រតិបត្តិតាមគន្លងព្រះនព្វលោកុត្តរធម៌ ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដោយត្រង់ គឺប្រតិបត្តិជាមជ្ឈិមប្បដិបទា ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដើម្បីត្រាស់ដឹងនូវព្រះនិព្វានជាស្ពានក្បៀមផុតចាកទុក្ខទាំងពួង សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដ៏សមគួរដល់សាមីចិកម្ម គឺប្រតិបត្តិគួរដល់សីល សមាធិ បញ្ញា យទិទំ ចត្តារិ បុរិសយុគានិ ព្រះសង្ឃឯណាបើរាប់ជាគូនៃបុរសទាំងឡាយមាន៤គូ

គឺព្រះសង្ឃដែលបានសម្រេចនូវសោតាបត្តិមគ្គនិង សោតាបត្តិផលជាគូ១ សកទាគាមិមគ្គនិង សកទាគាមិផលជាគូ១ អនាគាមិមគ្គនិងអនាគាមិផលជាគូ១ អរហត្តមគ្គនិងអរហត្តផលជាគូ១ អដ្ឋ បុរិសបុគ្គលា បើរាប់រៀងជាបុរស បុគ្គលមាន៨ គឺព្រះសង្ឃដែលបានសម្រេចនូវសោតាបត្តិមគ្គ១ សោតាបត្តិផល១ សកទាគាមិមគ្គ១ សកទាគាមិផល១ អនាគាមិមគ្គ១ អនាគាមិផល១ អរហត្តមគ្គ១ អរហត្តផល១ ឯស ភគវតោ សាវកសង្ឃោ ព្រះសង្ឃទាំងនុ៎ះជាសង្ឃសាវ័កនៃព្រះដ៏មានព្រះភាគ អាហុនេយ្យោ លោកគួរទទួលនូវចតុប្បច្ច័យដែលបុគ្គលឧទ្ទិសចំពោះអ្នកមានសីល ហើយនាំមកអំពីចម្ងាយ បង្អោនចូលមកបូជា បាហុនេយ្យោ លោកគួរទទួលនូវអាគន្តុកទាន គឺទានដែលបុគ្គលតាក់តែងដើម្បីញាតិនិងមិត្ត ដែលមកអំពីទិសផ្សេងៗហើយបង្អោនចូលមកបូជា ទក្ខិណេយ្យោ លោកគួរទទួលនូវទានដែលបុគ្គលជឿនូវកម្មនិងផលនៃកម្មហើយបូជា អញ្ជលិករណីយោ លោកគួរដល់ អញ្ជលិកម្ម ដែលសត្វលោកគប្បីធ្វើ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស លោកជាបុញ្ញក្ខេត្តគឺជាទីដុះឡើងនៃពូជគឺបុណ្យនៃសត្វលោករកខេត្តដទៃក្រៃលែងជាងគ្មាន តំ សុបដិបន្នាទិគុណសំយុត្តំ សង្ឃំ សិរសា នមាមិ ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវព្រះសង្ឃជាម្ចាស់ ដ៏ប្រកបព្រមហើយដោយ គុណមានគុណថា សុបដិបន្នោ ជាដើមនោះ ដោយសិរសាគឺត្បូង តញ្ច សង្ឃំ ឥមេហិ សក្ការេហិ អភិបូជយាមិ ខ្ញុំព្រះករុណាសូមបូជាចំពោះនូវព្រះសង្ឃជាម្ចាស់នោះដោយ គ្រឿងសក្ការៈទាំងឡាយមានប្រមាណប៉ុណ្ណេះ ។

( ក្រាបថ្វាយបង្គំម្តង )

ដកស្រង់និងចងក្រងដោយខ្ញុំបាទ **ខ៊ាន់ អ៊ុខ** អាចារ្យទី១សម្រាប់វត្តធម្មារាម ក្រុងស្តុកតុន រដ្ឋកាលីហ្វរនីញ៉ា ព.ស.២៥៤៣

វាយចម្លងដាក់គេហទំព័រវត្តដោយខ្ញុំបាទ **អ៊ិន ឈី** ថ្ងៃទី១៦ ខែមីនា គ.ស.២០១២

